ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៣៣ ៛ ៣៣៣

ក្រសួងអប់រំ យុវជន និង កីឡា
លេខ ១៣៩ អយក

# ប្រកាស
## ស្តីពីការបើកថ្នាក់បំពេញវិជ្ជាក្រៅម៉ោងធ្វើការ
## មធ្យមសិក្សាទុតិយភូមិ ខេត្តសៀមរាប

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស រកត ១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រម នស.រកម ០១៩៦.០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា ។
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ. បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា ។
- បានឃើញសេចក្តីសម្រេចលេខ ២២៦ អរ.សសរ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៨៧ ស្តីពីការបើកសាលាបំពេញវិជ្ជាក្រៅម៉ោងធ្វើការកំរិតសិក្សាទី ៣ ខេត្តសៀមរាប ។
- តាមសំណើរបស់មន្ទីរអប់រំ យុវជន និង កីឡាខេត្តសៀមរាប លេខ ៤១៤២ អយកខ.អកប ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ។
- តាមសំណូមពររបស់នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ។

**សម្រេច**

ប្រការ ១ : អនុញ្ញាតឱ្យមន្ទីរអប់រំ យុវជន និង កីឡាខេត្តសៀមរាប បើកថ្នាក់បំពេញវិជ្ជាក្រៅម៉ោងធ្វើការមធ្យមសិក្សាទុតិយភូមិ ចាប់ពីឆ្នាំសិក្សា ២០០៦-២០០៧ ដែលមានទីតាំងនៅវិទ្យាល័យ ១០ មករា ១៩៧៩។

ប្រការ ២ : ថ្នាក់បំពេញវិជ្ជាក្រៅម៉ោងធ្វើការមធ្យមសិក្សាទុតិយភូមិនេះ ត្រូវស្ថិតនៅក្រោមឱវាទផ្ទាល់នៃមន្ទីរអប់រំ យុវជន និង កីឡាខេត្តសៀមរាប ។

ប្រការ ៣ : នាយក នាយករង និង បុគ្គលិកនៃសាលាដែលមានថ្នាក់បំពេញវិជ្ជា មានភារកិច្ចបន្ថែមក្នុងការគ្រប់គ្រងដឹកនាំថ្នាក់បំពេញវិជ្ជានេះតាមការចាំបាច់ ។

ប្រការ ៤ : ប្រភពសិស្សចូលរៀនត្រូវទុកអាទិភាពឱ្យសិស្សរបស់សាលាផ្ទាល់ សិស្សដែលពុំបានរៀនបន្តនៅសាលាចំណេះទូទៅ ( ប្រឡងធ្លាក់២ដង) បុគ្គលិកអប់រំ និង មន្ត្រីរាជការដែលមានបំណងចង់រៀនសូត្របន្ថែម ។

ប្រការ ៥ : ប្រព័ន្ធអប់រំ កម្មវិធីសិក្សា និង បទបញ្ញត្តិផ្សេងៗ ត្រូវអនុវត្តតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

ប្រការ ៦ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

ប្រការ ៧ : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្តសៀមរាប និង នាយកថ្នាក់បំពេញវិជ្ជាក្រៅម៉ោងធ្វើការនេះមានភារកិច្ចអនុវត្តប្រកាសនេះរៀងៗខ្លួន ។

រាជធានីភ្នំពេញ, ថ្ងៃទី … ឆ្នាំ ២០០៧

ឧ.-ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

ម៉ក់_ទ៉ាន់

**<u>ចម្លងជូន</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  " ដើម្បីជូនជ្រាបជាព័ត៌មាន "
- សាលាខេត្ត សៀមរាប " ដើម្បីជ្រាបជាព័ត៌មាន "
- ដូចប្រការ ៧
- ឯកសារ
- កាលប្បវត្តិនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

អាស្រ័យដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៧ ២៥៣ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
Email: crsmeys@camnet.com.kh Web site: www.moeys.gov.kg